# សុន្ទរកថា
## ឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
## ក្នុងពិធីបិទវគ្គបណ្តុះបណ្តាល ស្តីពី
## «ការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣»

ទីស្តីការ គ.ជ.ប ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣

**ជាបឋម ខ្ញុំសូមគោរពអង្គពិធីទាំងមូលជាទីគោរព** !

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានចូលរួមជាមួយនឹង ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ក្នុងពិធីបិទវគ្គបណ្តុះបណ្តាល ស្តីពី «**ការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣**» ជូនដល់ប្រធាន សមាជិកនៃ គធ.ខប ប្រធាន លគធ.ខប មន្ត្រី គ.ជ.ប តំណាងស្ថាប័នជាតិ តំណាងក្រសួង តំណាងគណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាល ដ៏មានសារៈសំខាន់នាពេលនេះ ។

ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះអគ្គនាយកដ្ឋានជំនាញ នាយកដ្ឋានជំនាញ និងអង្គភាពពាក់ព័ន្ធ ព្រមទាំងសិក្ខាកាមទាំងអស់ ដែលបានសហការ និងចូលរួមយ៉ាងសកម្មធ្វើឱ្យដំណើរការវគ្គបណ្តុះបណ្តាលរយៈពេល ២ ថ្ងៃនេះ ប្រព្រឹត្តទៅបានដោយរលូន ស្របតាមផែនការ និងប្រតិទិនដែលបានកំណត់ ។

ផ្អែកតាមរបាយការណ៍បូកសរុបលទ្ធផលនៃវគ្គបណ្តុះបណ្តាលរបស់នាយកដ្ឋានជំនាញ ឃើញថាសិក្ខាកាមទាំងអស់មានការយល់ដឹងអំពីការឃោសនាបោះឆ្នោតបានល្អប្រសើរ តាមរយៈការលើកជាសំណួរផ្សេងៗ ករណីសិក្សា និងការអនុវត្តការសម្តែងតួស្តីពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងការឃោសនាបោះឆ្នោតនៅថ្នាក់ គឃ.សប និងនៅថ្នាក់ គធ.ខប ហើយគ្រូឧទ្ទេស និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប ក៏បានធ្វើការឆ្លើយបំភ្លឺជូនរួចហើយដែរ ។ កត្តានេះបានបង្ហាញពីភាពវិជ្ជមានសម្រាប់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាមន្ត្រី គធ.ខប និងភាគីពាក់ព័ន្ធ ដែលមានភារកិច្ចត្រូវផ្តល់ការបណ្តុះបណ្តាលបន្ត ដល់មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ និងភាគីពាក់ព័ន្ធ ឱ្យមានការយល់ដឹងកាន់តែច្បាស់បន្ថែមទៀតនៅថ្នាក់រាជធានី ខេត្ត អំពីការឃោសនាបោះឆ្នោត ដើម្បីចូលរួមសហការ និងអនុវត្តឱ្យបានត្រឹមត្រូវ និងប្រកបដោយបរិយាកាសល្អ តម្លាភាព ស្មើភាព យុត្តិធម៌ និងសុខដុមនីយកម្ម ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា**

ដើម្បីឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស គ.ជ.ប បានកសាងប្រតិទិន និងផែនការមេ និងបានអនុវត្តសម្រេចការងារតាមដំណាក់កាលនីមួយៗ ជាពិសេសការអនុម័តបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលជាឯកសារគតិយុត្តដ៏សំខាន់ សម្រាប់អនុវត្តការងារបច្ចេកទេសបោះឆ្នោតតាមដំណាក់កាលនីមួយៗ ។ បន្ថែមលើនេះ គ.ជ.ប បានដាក់បញ្ចូលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីជាជំនួយដល់ការអនុវត្តដោយដៃរបស់មន្ត្រីបោះឆ្នោត សំដៅរៀបចំ ចាត់ចែង និងគ្រប់គ្រងដំណើរការបោះឆ្នោត ឱ្យកាន់តែល្អប្រសើរ មានតម្លាភាព និងសុក្រិតភាពថែមមួយកម្រិតទៀត ។

ទោះជាយ៉ាងណាក៏ដោយ ក្រៅពីការកសាងលិខិតបទដ្ឋានគតិយុត្តដែលមានលក្ខណៈល្អប្រសើរ និងគ្រប់ជ្រុងជ្រោយ ការបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពដល់មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ព្រមទាំងភាគីពាក់ព័ន្ធឱ្យមានការយល់ដឹងច្បាស់លាស់អំពីច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត គឺជាកត្តាសំខាន់ដែល គ.ជ.ប ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យហ្មត់ចត់ ហើយនេះគឺជាហេតុផលសំខាន់នាំឱ្យយើងមានការជួបជុំគ្នាក្នុងវគ្គបណ្តុះបណ្តាលនាពេលនេះ ។

តាមរយៈវគ្គបណ្តុះបណ្តាលនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលជាសិក្ខាកាមទាំងអស់នឹងទទួលបាននូវចំណេះដឹង និងបទពិសោធន៍ថ្មីបន្ថែមទៀត ពាក់ព័ន្ធនឹងដំណើរការរៀបចំការបោះឆ្នោត ជាពិសេសការឃោសនាបោះឆ្នោត ដែលត្រូវត្រូវចាប់អនុវត្តពីថ្ងៃទី១ ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមធ្វើការអំពាវនាវដល់គ្រប់គណបក្សនយោបាយ បេក្ខជនឈរឈ្មោះ និងអ្នកគាំទ្រទាំងអស់ ត្រូវតែគោរពតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ ក្រមសីលធម៌សម្រាប់ការបោះឆ្នោត គោលការណ៍ស្តីពីសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងនោះ ៖

- គ្រប់បេក្ខជន និងគណបក្សនយោបាយទាំងអស់ត្រូវប្រកាន់អាកប្បកិរិយាថ្លៃថ្នូរ
- គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់មិនត្រូវបង្គាប់បញ្ជាឱ្យអ្នកគាំទ្ររបស់ខ្លួនទៅហែក ឬបំផ្លាញចោលសម្ភារ ឯកសារឃោសនារបស់គណបក្សនយោបាយ ឬ/និងបេក្ខជនដទៃឡើយ
- គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ ត្រូវចៀសវាងប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត
- គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវញុះញង់ អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀតឡើយ
- គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យអសីលធម៌ ប្រមាថ មាក់ងាយទៅលើបេក្ខជន ឬអ្នកគាំទ្រ ឬលើបុគ្គលណាម្នាក់ឡើយ
- គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រទាំងអស់ មិនត្រូវធ្វើការ គំរាមកំហែង បំភិតបំភ័យ និងលួងលោមឱ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យា បោះឆ្នោតឱ្យគណបក្សនយោបាយណាមួយឡើយ
- គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវផ្តល់ អំណោយជាថវិកា ឬជាសម្ភារដែលជារង្វាន់លើកទឹកចិត្ត វិភាគទាន ជូនសគុណ ឬរង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារ ទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត

- គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវញុះញង់ឱ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់
- គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវគំរាមកំហែង ឬបំភិតបំភ័យដោយផ្ទាល់ ឬដោយប្រយោលដល់បុគ្គលណាម្នាក់ ឬក្រុមគ្រាំទ្រណាមួយ ដើម្បីឱ្យគេគាំទ្រខ្លួន ឬបំបាក់ទឹកចិត្តបុគ្គលទាំងនោះឱ្យឈប់គាំទ្រដល់បេក្ខជន ឬគណបក្សនយោបាយដទៃទៀតឡើយ។

ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលបំពេញការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹត ឥតលម្អៀង នៅក្នុងការឃោសនាបោះឆ្នោត និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា**

ចំពោះខ្លឹមសារ និងគោលការណ៍សំខាន់ដែលបានចែងនៅក្នុងច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត និងសេចក្តីណែនាំនានារបស់ គ.ជ.ប ពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត ត្រូវបានគ្រូឧទ្ទេសជំនាញតាមប្រធានបទនីមួយៗដាក់បញ្ចូលទៅក្នុងបទបង្ហាញ និងបានពន្យល់ បកស្រាយ លើកជាឧទាហរណ៍ ករណីសិក្សា និងធ្វើការសម្តែងតួជូនដល់អង្គពីធីទាំងមូល ដូចនេះខ្ញុំជឿជាក់ថាសិក្ខាកាមទាំងអស់ប្រាកដជាបានយល់ច្បាស់ហើយនូវបទប្បញ្ញត្តិ និងនីតិវិធីដែលនឹងត្រូវអនុវត្តក្នុងដំណាក់កាលឃោសនាបោះឆ្នោត នាពេលខាងមុខនេះ ។

បន្ទាប់ពីវគ្គបណ្តុះបណ្តាលនេះទៅ គជ.ខប ទាំងអស់ត្រូវត្រៀមរៀបចំសម្ភារឧបទ្ទេស និងត្រៀមលក្ខណៈដើម្បីធ្វើការបណ្តុះបណ្តាលបន្តទៅមន្ត្រី គជ.ខប មន្ត្រី លគជ.ខប និងភាគីពាក់ព័ន្ធផ្សេងទៀតក្នុងក្របខណ្ឌរាជធានី ខេត្តរបស់ខ្លួន និងបន្តទៅធ្វើការបណ្តុះបណ្តាលជូន គឃ.សបដែលនឹងត្រូវតែងតាំងនាពេលខាងមុខនេះ នៅតាមមណ្ឌលប្រមូលផ្តុំក្រុង ស្រុក ខណ្ឌ ស្របតាមផែនការ និងប្រតិទិនដែលបានកំណត់ និងតាមគោលការណ៍ណែនាំរបស់ គ.ជ.ប ព្រមទាំងគោរពឱ្យនូវវិធានការនានា ដើម្បីបង្ការ និងទប់ស្កាត់ការឆ្លងរាលនៃជំងឺកូវីដ-១៩ ។ ទន្ទឹមនឹងនេះ ខ្ញុំសូមស្នើសុំទៅភាគីពាក់ព័ន្ធមេត្តាជួយផ្សព្វផ្សាយបន្ត ដើម្បីអប់រំដល់សាធារណជនអំពីការឃោនាបោះឆ្នោត ព្រមទាំងចូលរួមសហការអនុវត្តតាមតួនាទី និងភារកិច្ចរៀងៗខ្លួន សំដៅធានាឱ្យដំណើរការឃោសនាបោះឆ្នោតប្រព្រឹត្តទៅក្នុងសភាពការណ៍មានសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ល្អ មានភាពចាស់ទុំ មានភាពថ្លៃថ្នូរ ចៀសវាងការជេរប្រមាថ ការញុះញង់ ការអុជអាលនាំឱ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធុ ក្រុមជាតិពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់ ដើម្បីបង្កបរិយាកាសល្អដល់ដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងសិក្ខាកាមទាំងអស់ ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ និងសូមប្រសិទ្ធពរជ័យជូនដល់អង្គពិធីទាំងមូល សូមទទួលបាននូវពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណកុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសបិទវគ្គបណ្តុះបណ្តាលស្តីពី «**ការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣**» ចាប់ពីពេលនេះតទៅ ។

*សូមអរគុណ!*